ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# មតិសំណេះសំណាល
# លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារពុទ្ធិកសិក្សារាជបូណ៌

ខេត្តសៀមរាប ថ្ងៃសុក្រ ១២រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤

**សូមក្រាបថ្វាយបង្គំ៖**

- **សម្តេចព្រះពុទ្ធជ័យមុនីបណ្ឌិត ឃឹម សន** សម្តេចព្រះសង្ឃនាយករងទី៣ គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម** ឧត្តមទីប្រឹក្សាគណៈសង្ឃនាយក គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌
- **សម្តេចព្រះឧត្តមចរិយាបណ្ឌិត ឈឹង ម៉ុនឈា** អនុប្រធានថេរសភាពុទ្ធសាសនា
- **សម្តេចព្រះមហាអរិយវង្សបណ្ឌិត យ៉ន សេងយៀត** ព្រះសាកលវិទ្យាធិការ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
- **សម្តេចព្រះមង្គលមុនីវង្ស ហ៊ូ ឈីវនាថ** អនុប្រធានអចិន្ត្រៃយ៍ លេខាធិការដ្ឋាន គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ និង
- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!

**សូមគោរព៖**

- ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តសៀមរាប
- ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ បងប្អូនពុទ្ធបរិស័ទទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធ នាពេលនេះ!

១/- ថ្ងៃនេះ ខ្ញុំព្រះករុណានាងខ្ញុំ មានសេចក្តីសោមនស្សយ៉ាងក្រៃលែងដែលបានមកជួបជាមួយសម្តេច ព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ និងបងប្អូនពុទ្ធបរិស័ទទាំងអស់ ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារពុទ្ធិកសិក្សារាជបូណ៌ នាឱកាសដ៏វិសេសវិសាលនេះ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

២/- ក្រោមព្រះទ័យផ្តួចផ្តើមរបស់ **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម** និងកិច្ចគាំទ្រទាំងស្មារតី និងសម្ភារៈរបស់ **ឯកឧត្តម ជា ចាន់តូ** និងលោកជំទាវ **ខៀវ ស៊ីណា** ដែលលោកទាំងពីរជាពុទ្ធបរិស័ទគោរពយ៉ាងខ្ជាប់ខ្ជួន និងដើរតាមមាគ៌ាព្រះពុទ្ធសាសនា ដោយជានិច្ចកាល លោកទាំងពីរតែងតែជួយជ្រោមជ្រែងឧបត្ថម្ភដល់ការកសាងអគារពុទ្ធិកសិក្សា វត្តអារាម គ្រឿងសម្ភារៈប្រើប្រាស់ និងសិក្សាសម្រាប់ជាថ្នាលបណ្តុះបណ្តាល ចំណេះដឹងផ្នែកព្រះពុទ្ធសាសនា និងការបោះពុម្ពសៀវភៅធម៌ ដើម្បីជាធម្មទានដល់វត្តអារាមនានា។ ខ្ញុំព្រះករុណានាងខ្ញុំ សូមបួងសួង និងឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធរបស់ **ឯកឧត្តម ជា ចាន់តូ** ឱ្យបានដល់ទីបរមសុខ កុំបីឃ្លៀងឃ្លាតឡើយ។

៣/- វត្តរាជបូណ៌ ឬវត្តបូណ៌ ដែលពីបុរាណហៅថា **វត្តបូទុមកេសរ** ត្រូវបានកសាងឡើងនៅឆ្នាំ១៦៥០ ក្នុងរជ្ជកាលសម្តេចព្រះបាទ នរោត្តម ដែលស្ថិតនៅភូមិវត្តបូណ៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។ គួររំលឹកផងដែរថា ក្នុងរបបប្រល័យពូជសាសន៍ ព្រះពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញ និងលុបបំបាត់យ៉ាងសាហាវនិងផ្តាច់ការ ដោយព្រះសង្ឃត្រូវបានបង្ខំឱ្យលាចាកសិក្ខាបទ ដើម្បីធ្វើការងារពលកម្មដូចប្រជាជនទូទៅ និងជាពិសេស ក្បួនច្បាប់និងគម្ពីរព្រះពុទ្ធសាសនាជាច្រើន ត្រូវបានកំទេចចោល ប៉ុន្តែក្រោយជ័យជំនះ ៧ មករា ១៩៧៩ ប្រទេសកម្ពុជាបានជ្រកក្រោមម្លប់សន្តិភាពពេញលេញ ដែលអនុញ្ញាតឱ្យប្រជាជនខ្មែរមានសិទ្ធិក្នុងការគោរពបូជាសាសនា ធ្វើបុណ្យទានដោយចិត្តជ្រះថ្លា និងសេរីភាព ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ចាប់តាំងពីពេលបង្កើតរហូតដល់បច្ចុប្បន្ន វត្តរាជបូណ៌ មានព្រះគ្រូចៅអធិការចំនួន ១០អង្គ ដោយបច្ចុប្បន្នមាន **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម** ជាព្រះគ្រូចៅអធិការ ដែលសម្តេចបានរៀបចំឱ្យមានសាលាពុទ្ធិកវិទ្យាល័យ ដែលមានបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ បាលីសំស្ក្រឹត ព្រះពុទ្ធសាសនា សីលធម៌ រូបវិទ្យា គីមីវិទ្យា គណិតវិទ្យា សង្គមវិទ្យា វិទ្យាសាស្ត្រ និងមានសមណសិស្សប្រមាណជាង ៥០០អង្គ បានធ្វើការសិក្សាជារៀងរាល់ឆ្នាំ។ សម្តេចបានរៀបចំបង្កើតឱ្យមានស្ថានីយវិទ្យុសម្រាប់ផ្សព្វផ្សាយដល់គ្រប់ទីកន្លែង ទាំងវិស័យព្រះពុទ្ធសាសនា វប្បធម៌ និងការអប់រំនានា សំដៅរក្សានិងលើកតម្កើងតម្លៃព្រះពុទ្ធសាសនា និងអភិរក្សវប្បធម៌ ព្រមទាំងបង្កើតមជ្ឈមណ្ឌលវប្បធម៌និងសិល្បៈសម្រាប់បង្ហាត់បង្រៀនចំណេះដឹងខាងផ្នែករបាំ ផ្នែកចម្លាក់ក្បាច់និងគំនូរ ផ្នែកភ្លេងបុរាណ មានទាំងស្បែកតូច ស្បែកធំ ភ្លេងពិណពាទ្យ និងភ្លេងប្រពៃណី ដើម្បីរក្សាវប្បធម៌ឱ្យផ្សរផង់ រស់រវើក និងថ្កុំថ្កើង។ បន្ថែមពីនេះ សម្តេចបានផ្តួចផ្តើមកសាងព្រះវិហារ ឧបដ្ឋានសាលា កុដិ សាលាបាលី និងសាលាសិល្បៈ ដើម្បីទុកជាកេរ្តិ៍មរតកសម្រាប់កូនចៅជំនាន់ក្រោយផងដែរ។ ព្រះគំរូវីរភាព សមិទ្ធផល និងស្នាដៃដ៏ឧត្តុង្គឧត្តមទាំងអស់នេះ ជាការរួមចំណែកដ៏ធំធេងរបស់ **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម** ក្នុងការថែរក្សាតម្លៃព្រះពុទ្ធសាសនា ក៏ដូចជាការរក្សាមរតកវប្បធម៌ជាតិឱ្យរុងរឿង។

**- សម្តេច ព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ និងបងប្អូនពុទ្ធបរិស័ទទាំងអស់!**

៤/- ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណានាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅប្រគេនចំពោះ សម្តេចព្រះព្រហ្មរតនមុនី ពិន សែម ព្រះគ្រូចៅអធិការវត្តរាជបូណ៌ ដែលបានផ្តួចផ្តើមព្រះទ័យក្នុងការ កសាងអគារពុទ្ធិកសិក្សារាជបូណ៌នេះ សម្រាប់ប្រគេនការអប់រំដល់ព្រះសង្ឃផង និងទុកជាកេរដំណែល ព្រះពុទ្ធសាសនាផង។ អគារពុទ្ធិកសិក្សារាជបូណ៌នេះ សាងសង់លើផ្ទៃដីទំហំ ៣៤២ ម៉ែត្រការ៉េ ដែលមានបណ្តោយ ៣៦ ម៉ែត្រ និងទទឹង ៩,៥ ម៉ែត្រ និងមានកម្ពស់ ៤ជាន់ រួមទាំងជាន់ផ្ទាល់ដី ដែលមានបណ្ណាល័យចំនួន ១ សាលប្រជុំធំចំនួន ១ និងបន្ទប់រដ្ឋបាលចំនួន ១ ហើយបីជាន់ខាងលើជា បន្ទប់សិក្សាសរុបចំនួន ១២ បន្ទប់ ដែលក្នុងនោះមាន កុំព្យូទ័រលើតុចំនួន ៣០គ្រឿង, LCD Projector និងស្គ្រីន LCD (Screen LCD) ចំនួន ៣ឈុត, ម៉ាស៊ីនត្រជាក់ ចំនួន ៥គ្រឿង, កង្ហារ ៦៤គ្រឿង, តុកៅអី សរុបចំនួន ៤៧៩ និងសម្ភារៈគ្រឿងបរិក្ខារចាំបាច់ផ្សេងៗមួយចំនួនទៀត។

៥/- ជាថ្មីម្តងទៀត ខ្ញុំព្រះករុណានាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលជា សប្បុរសជន ជាពិសេស ១/- ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកទាំងអស់នៃធនាគារជាតិនៃកម្ពុជា ២/- ធនាគារ អេស៊ីលីដា ភីអិលស៊ី ៣/- ធនាគារ អ៊ីវី (ខេមបូឌា) ម.ក ៤/- ធនាគារ ខេប៊ី ប្រាសាក់ ម.ក និង ៥/- បរធនបាលកិច្ចហិរញ្ញវត្ថុ ប្រាសាក់ ព្រមទាំងគ្រឹះស្ថានផ្សេងៗទៀត ដែលបានរួមចំណែកកសាង សមិទ្ធផលជាច្រើន និងចូលរួមវិភាគទានដល់ការកសាងអគារពុទ្ធិកសិក្សារាជបូណ៌តាំងពីថ្ងៃបញ្ចុះ បឋមសិលាសាងសង់រហូតដល់សាងសង់រួចរាល់ជាស្ថាពរនាពេលនេះ ដើម្បីជាប្រយោជន៍ដល់សង្គម ជាតិផង និងព្រះពុទ្ធសាសនាផង។

៦/- ខ្ញុំព្រះករុណានាងខ្ញុំ ក៏សង្ឃឹមយ៉ាងមុតមាំថា ការបណ្តុះបណ្តាល និងការអប់រំផ្នែកព្រះពុទ្ធ សាសនានៅខេត្តសៀមរាបផ្តើមចេញពីវត្តរាជបូណ៌ ក្រោមការដឹកនាំរបស់ **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម ព្រះគ្រូចៅអធិការវត្តរាជបូណ៌** នឹងរីកដុះដាលកាន់តែខ្លាំង ព្រមទាំងជំរុញឱ្យមានការកសាង ពុទ្ធិកសិក្សានៅតាមវត្តអារាមនានាជាបន្តបន្ទាប់ ទាំងកម្រិតបឋម មធ្យម និងឧត្តម ដើម្បីបណ្តុះចំណេះដឹង កាន់តែប្រសើរឡើងដល់ធនធានព្រះសង្ឃ ដើម្បីភាពរុងរឿងនៃព្រះពុទ្ធសាសនា និងសង្គមកម្ពុជា។

៧/- ទន្ទឹមនេះ ថ្ងៃនេះ ខ្ញុំព្រះករុណានាងខ្ញុំ តំណាងសប្បុរសជននានា ក៏បាននាំយកនូវ អំណោយ និងប្រាក់ឧបត្ថម្ភ ដើម្បីប្រគេនព្រះតេជគុណ ព្រះថេរានុត្ថេរៈ សមណសិស្ស និងចែកជូន គ្រូបង្រៀន អាចារ្យ និងតាជី-យាយជី ព្រមទាំងគណៈកម្មការ និងក្រុមការងារជាង សរុបប្រមាណ ២៩២អង្គ/នាក់ ដែលក្នុងនោះរួមមាន៖

១/- ប្រគេនព្រះមេគណខេត្តទាំងពីរគណៈ ក្នុងមួយអង្គប្រគេនសាដក ១ និងបច្ច័យ ៥០០.០០០រៀល

២/- ប្រគេនព្រះអនុគណចំនួន ១២អង្គ ក្នុងមួយអង្គប្រគេនសាដក ១ និងបច្ច័យ ៥០០.០០០រៀល

៣/- ប្រគេនព្រះចៅអធិការចំនួន ៤១ អង្គ ក្នុងមួយអង្គប្រគេនសាដក ១ និងបច្ច័យ ៥០០.០០០រៀល

៤/- ប្រគេនព្រះមន្ត្រីសង្ឃចំនួន ៧អង្គ ក្នុងមួយអង្គប្រគេនសាដក ១ និងបច្ច័យ ២០០.០០០រៀល

៥/- ប្រគេនព្រះសង្ឃវត្តព្រះរាជបូណ៌ចំនួន ២៩អង្គ ក្នុងមួយអង្គប្រគេនសាដក ១ និងបច្ច័យ ១០០.០០០រៀល

៦/- ប្រគេនសមណសិស្សចំនួន ១០០អង្គ ក្នុង១អង្គប្រគេនសាដក ១ និងបច្ច័យ ១០០.០០០រៀល

៧/- ជូនគ្រូបង្រៀនចំនួន ៣៣នាក់ ក្នុងម្នាក់ទទួលបានថវិកា ១០០.០០០រៀល និងសារុង១

៨/- ជូនអាចារ្យចំនួន ៧នាក់ និងតាជី-យាយជីចំនួន ៣៥នាក់ ក្នុងម្នាក់ទទួលបានថវិកា ៥០.០០០រៀល និងក្រណាត់ស ១ដុំ និង

៩/- ជូនគណៈកម្មការចំនួន ១៨នាក់ និងក្រុមការងារជាងចំនួន ៨នាក់ ក្នុងម្នាក់ទទួលបានថវិកា ៥០.០០០រៀល និងសារុង ១។

**- សម្តេច ព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ និងបងប្អូនពុទ្ធបរិស័ទទាំងអស់!**

៨/- នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណានាងខ្ញុំ សូមប្រគេនពរចំពោះ សម្តេច ព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូម ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនប្រជាពលរដ្ឋទាំងអស់ សមប្រកបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

- សូមឧទ្ទិសមគ្គផលពិធីបុណ្យនេះជូនចំពោះបងប្អូនពុទ្ធបរិស័ទឱ្យបានបុណ្យស្មើៗគ្នា។

**សូមអរព្រះគុណ និងអរគុណ!**